C20/I/13

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

**អង្គបុរេជំនុំជម្រះ**
PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE

**សំណុំរឿងព្រហ្មទណ្ឌលេខ: ០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ០២)**

**អង្គបុរេជំនុំជម្រះ**

**ចំពោះមុខ:** ចៅក្រម ប្រាក់ គឹមសាន, ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម ន៉ីយ ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

**កាលបរិច្ឆេទ:** ០១ មេសា ២០០៨

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 01 / 04 / 2008
ម៉ោង (Time/Heure): 14:55'
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: NUP SOTHUNVUTHY

---

សាធារណៈ

**សេចក្តីសម្រេចលើសំណើសុំពន្យារពេលសវនាការលើបណ្តឹងឧទ្ធរណ៍ ជំទាស់នឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន**

---

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 01 / 04 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: [signature]

**សហព្រះរាជអាជ្ញា**
ជា លាង
Robert PETIT

**ជនត្រូវចោទ**
អៀង ធីរិទ្ធ

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
ហុង គឹមសួន
ឡោ ជុនធី
នី ចាន់ឌី
Silke Studzinsky

**សហមេធាវីការពារក្តី**
ផាត់ ពៅស៊ាង
Diana ELLIS

អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

# អង្គបុរេជំនុំជម្រះ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា "អវតក"

១. បានទទួល សំណើសុំពន្យារពេលសវនាការលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ដែលបានដាក់ជូនមកក្នុងនាម អៀង ធីរិទ្ធ នៅថ្ងៃទី២១ ខែមីនា ឆ្នាំ២០០៨ ( "សំណើសុំ" ) ។

២. នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០៨ សហព្រះរាជអាជ្ញា បានដាក់ជូននូវចម្លើយតបរបស់ខ្លួនតាមសេចក្តីបង្គាប់របស់អង្គបុរេជំនុំជម្រះ ។ សហព្រះរាជអាជ្ញា មិនជំទាស់នឹងសំណើសុំនេះទេ ប៉ុន្តែបានកត់សំគាល់ថា សហព្រះរាជអាជ្ញានិងប្រកាន់យកជំហរមួយផ្សេងវិញ ប្រសិនបើសំណើសុំពន្យារពេលនេះ អាចនឹងមានការប៉ះពាល់ខ្លាំងដល់ការរីកចំរើននៃដំណើរការស៊ើបសួរ ។

៣. មេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណី មិនបានដាក់ចម្លើយតបតាមកាលកំណត់ឡើយ ។

៤. នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០០៨ អង្គបុរេជំនុំជម្រះបានកំណត់កាលបរិច្ឆេទសវនាការ លើបណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន គឺសវនាការនេះនឹងត្រូវធ្វើឡើង នៅថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៨ ។ ក្នុងសំណើសុំ បានបញ្ជាក់ថា សហមេធាវីអន្តរជាតិសម្រាប់ អៀង ធីរិទ្ធ មិនអាចចូលរួមក្នុងសវនាការ តាមកាលកំណត់បានទេ ដោយសារកំពុងរង់ចាំការបំពេញបែបបទឱ្យបានចប់សព្វគ្រប់សម្រាប់ការការពារក្តីនៅចំពោះមុខ អ.វ.ត.ក ។

៥. ក្នុងការកំណត់កាលបរិច្ឆេទសវនាការ អង្គបុរេជំនុំជម្រះត្រូវពិចារណាទៅលើផលប្រយោជន៍នៃដំណើរការនីតិវិធីឆាប់រហ័ស និងផលប្រយោជន៍ផ្សេងៗទៀត រួមទាំងផលប្រយោជន៍របស់ជនត្រូវចោទផងដែរ ។ ជនត្រូវចោទអាចធ្វើការជ្រើសរើស ឱ្យតែមេធាវីជាតិតំណាងឱ្យខ្លួនក្នុងពេលសវនាការ និង ទទួលបានសវនាការយ៉ាងឆាប់រហ័ស ។ អង្គបុរេជំនុំជម្រះ ត្រូវបានជូនដំណឹងតាមរយៈសំណើសុំថា ជនត្រូវចោទមានបំណងសុំពន្យារពេលសវនាការ ដើម្បីអាចត្រូវបានតំណាងដោយទាំងមេធាវីជាតិ និងមេធាវីអន្តរជាតិតាមការជ្រើសរើសរបស់ខ្លួន ។ យោងតាមកាលៈទេសៈទាំងនេះ និងដោយសារការពន្យារពេលនេះពុំប៉ះពាល់ ដល់ផលប្រយោជន៍ណាមួយនោះ អង្គបុរេជំនុំជម្រះទទួលយកសំណើសុំនេះ ។

អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

## ហេតុដូច្នេះអង្គបុរេជំនុំជម្រះសម្រេច

ពន្យារពេល សវនាការលើបណ្តឹងឧទ្ធរណ៍ទាស់នឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ដល់**ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៨** ។

ភ្នំពេញ, ថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៨

**ប្រធានអង្គបុរេជំនុំជម្រះ**

**ប្រាក់ គឹមសាន**